ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ ក្រុមអ្នកដឹកនាំ RtII របស់ក្រសួង

*សហការជាមួយ* **ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និង សហគមន៍**





## ស្វែងយល់អំពី ការឆ្លើយតបទៅនឹង ការបង្ហាត់បង្រៀន និងការធ្វើអន្តរាគមន៍ (RtII)

# RtII និង សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស

ការិយាល័យផ្នែក កម្មវិធី និងកម្មវិធីសិក្សា ភាសាចម្រុះ មើលខុសត្រូវលើកម្មវិធី អង់គ្លេសសម្រាប់អ្នកដែលនិយាយភាសាដ៏ទៃទៀត (ESOL) និងកម្មវិធីពីរភាសា នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ គោលបំណងធំបំផុតរបស់យើងគឺ ដើម្បីបង្កើនល្បឿននៃការរីកចម្រើន ក្នុងការសិក្សា និងទំនាក់ទំនងក្នុងសង្គម របស់សិស្ស ELLs របស់យើង តាមរយៈការគាំទ្រ និងការតាមដានសាលា និងការឆ្លើយតប ព្រមទាំងការគាំទ្រ ដល់ក្រុមគ្រួសារឲ្យកាន់តែច្រើនឡើង។ យើងចង់ធ្វើយ៉ាងណាឲ្យសិស្សានុសិស្សទាំងអស់ ដែលជាសិស្ស ELLs រួមទាំងក្មេងអន្តោប្រវេសន៍ និងយុវវ័យ ឲ្យទទួលបាននូវ ការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស ជោគជ័យក្នុងការសិក្សាតាមកម្រិតខ្ពស់ ហើយសិក្សាបានតាមកម្រិតជាទូទៅ ដូចជាការដែលគេចង់បាន សម្រាប់ក្មេងទាំងអស់អញ្ចឹងដែរ។

ការិយាល័យផ្នែក កម្មវិធី និងកម្មវិធីសិក្សា ភាសាចម្រុះ គាំទ្រដល់គំរូ RtII របស់ក្រសួង តាមរយៈវិធីមួយចំនួន។ ដោយសារសិស្សដែលត្រូវការរៀនភាសាអង់គ្លេស ត្រូវគេរួមបញ្ចូលក្នុងការបង្ហាត់បង្រៀននៃដំណាក់កាលទី I យើងផ្តល់ការហ្វឹកហ្វឺនដល់គ្រូទូទាំងក្រសួង អំពីការបង្ហាត់បង្រៀនដែលមានប្រសិទ្ធិភាព សម្រាប់សិស្សដែលត្រូវការរៀនភាសាអង់គ្លេស។ យើងក៏ផ្តល់ជំនួយដល់គ្រូ ក្នុងការកត់សម្គាល់សិស្សណាដែលត្រូវការការជួយធ្វើអន្តរាគមន៍ នៃដំណាក់កាលទី II និងទី III និងជ្រើសរើសការធ្វើអន្តរាគមន៍ ដែលបានបង្ហាញឲ្យឃើញថាមានជោគជ័យដល់សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស។ ជាបន្ថែមទៀត យើងផ្តល់អ្នកជំនាញផ្នែក RtII របស់ក្រសួង ជាមួយនឹង ការហ្វឹកហ្វឺន និងការណែនាំ អំពីការតាមដានការរីកចម្រើន និងការបង្កើតផែនការបង្ហាត់បង្រៀន សម្រាប់សិស្សានុសិស្ស។

បណ្តាញសិក្សានីមួយៗ មានការចាត់តាំងអ្នកគ្រប់គ្រងផ្នែកភាសាចម្រុះ ដែលអាចជួយគ្រូ នៅពេលដែលពួកគាត់ត្រូវការជំនួយ។ ហើយក៏មានអ្នកឯកទេសផ្នែកកម្មវិធីសិក្សានៅក្រសួង ដែលចូលរួមបម្រើក្នុងក្រុមអ្នកដឹកនាំ RtII។

## សំណួរដែលមាតាបិតារបស់ សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស អាចសួរអំពី RTII

### តើលក្ខណៈពិសេសៗរបស់ RTII សម្រាប់សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស មានអ្វីខ្លះ?

មូលដ្ឋាននៃគំរូ RtII គឺការបង្ហាត់បង្រៀនដែលមានគុណភាពខ្ពស់។ សម្រាប់សិស្សានុសិស្សដែលត្រូវការរៀនភាសាអង់គ្លេស រួមមាន កម្មវិធី ESOL ប្រចាំថ្ងៃ និងការបង្ហាត់បង្រៀនមុខវិជ្ជាសំខាន់ៗ ដែលបានរៀបចំឡើងឲ្យស្របតាមកម្រិតស្ទាត់ជំនាញនៃភាសារបស់ពួកគេ។ គ្រូទាំងអស់ រួមបញ្ចូលវិធីសាស្ត្រនៃការបង្ហាត់បង្រៀន និងជំនួយ ដែលសម្រួលដល់ការសិក្សាភាសា សម្រាប់ទំនាក់ទំនងក្នុងសង្គម និងការសិក្សាវិទ្យាទូទៅ ដែលសិស្សានុសិស្សត្រូវការដើម្បីឲ្យមានជោគជ័យនៅក្នុងថ្នាក់រៀន។



## តើគេសម្គាល់កូនរបស់ខ្ញុំសម្រាប់ការធ្វើអន្តរាគមន៍ ដោយរបៀបណា?

ដោយសារកម្មវិធី ESOL ជាមុខវិជ្ជាសំខាន់មួយនៅក្នុងរដ្ឋវិនស៊ីលវេញ៉ា កម្មវិធីនេះត្រូវស្ថិតនៅក្នុងដំណាក់កាលទី I ឬជាការបង្ហាត់បង្រៀនសំខាន់។ គ្រូបានទទួលការហ្វឹកហ្វឺនក្នុងការរៀបចំផែនការសម្រាប់ មុខវិជ្ជា និង ភាសា ដែលអាចជួយសិស្សានុសិស្សឲ្យពុះពារបាននូវការលំបាកក្នុងការសិក្សាមុខវិជ្ជាតាមរយៈភាសាថ្មី។ មុននឹងចាត់តាំងការធ្វើអន្តរាគមន៍ និង ជំនួយបន្ថែម គ្រូត្រូវគិតដល់ វប្បធម៌ និងកម្រិតចំណេះដឹងនៃភាសា របស់សិស្ស។ ពួកគេនឹងសម្រេចថាតើសិស្សមាន ការលូតលាស់ ការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស គ្រប់គ្រាន់ឬអត់ នៅពេលប្រៀបធៀបជាមួយសិស្សដែលត្រូវការរៀនភាសាអង់គ្លេសផ្សេងទៀត ហើយថាតើសិស្សមានជោគជ័យជាមួយការបង្ហាត់បង្រៀនមុខវិជ្ជា ESOL និងមុខវិជ្ជាសំខាន់ៗ ដែលរួមទាំង ការគាំទ្រ និងឱកាសគ្រប់គ្រាន់ដើម្បីអភិវឌ្ឍភាសាសម្រាប់ ការទាក់ទង និងសម្រាប់មុខវិជ្ជាសិក្សា ដែរឬអត់។

បើសិនជាសិស្សរៀនមិនទាន់គេនូវមុខវិជ្ជាអ្វីមួយ គ្រូ ESOL និងអ្នកគ្រប់គ្រងផ្នែកភាសាចម្រុះ អាចសំណូមពរឲ្យផ្លាស់ប្តូរប្រភេទ ឬចំនួនម៉ោងបង្ហាត់បង្រៀន ESOL ឬផ្តល់ជំនួយដល់គ្រូប្រចាំថ្នាក់ ដើម្បីជួយសិស្សឲ្យទទួលបានជោគជ័យ។ ហើយពួកគេក៏សហការជាមួយក្រុមគ្រូបង្រៀន ដើម្បីសម្រេចពីពេលវេលាដែលសមរម្យដើម្បីដាក់សិស្សទៅក្នុងការជួយធ្វើអន្តរាគមន៍នៃដំណាក់កាលទី II។

## តើត្រូវធ្វើដូចម្តេច បើសិនជាកូនខ្ញុំរៀនមិនទាន់គេនូវមុខវិជ្ជាអ្វីមួយ បើប្រៀបធៀបជាមួយសិស្សានុសិស្សដ៏ទៃទៀត ដែលការស្ទាត់ជំនាញផ្នែកភាសា មានកម្រិតស្មើគ្នា?

បើសិនជាកូនលោកអ្នកគ្មានការរីកចម្រើន ស្មើនឹងសិស្សានុសិស្សដទៃទៀត គ្រូ ESOL និង គ្រូប្រចាំថ្នាក់ នឹងសហការគ្នា ដើម្បីប្រមូលព័ត៌មានបន្ថែម អំពីមូលហេតុដែលនាំឲ្យកូនលោកអ្នកមានការលំបាក។ ពិន្ទុពីថ្នាក់រៀន ការវាយតម្លៃ benchmark គំរូនៃកិច្ចការ និងការវាយតម្លៃអំពីការវិភាគពីមូលហេតុនៃបញ្ហា អាចយកមកពិនិត្យឡើងវិញ។ ពួកគេក៏ធ្វើការពិចារណាអំពី ភាសា និងវប្បធម៌ ដែលអាចជាមូលហេតុដែលនាំមកនូវការលំបាកដល់កូនរបស់លោកអ្នក។ បន្ទាប់មក គ្រូនឹងសហការគ្នា ដើម្បីជ្រើសរើសការធ្វើអន្តរាគមន៍ដែលល្អ សម្រាប់កូនលោកអ្នក។ ជាការសំខាន់ដែលត្រូវជ្រាបថា ការធ្វើអន្តរាគមន៍នៃដំណាក់កាលទី II គឺជាការជួយបន្ថែមទៅលើការបង្ហាត់បង្រៀនដែលសិស្សកំពុងទទួល ហើយមិនត្រូវរំខានដល់ការបង្ហាត់បង្រៀន ESOL របស់កូនលោកអ្នកទេ។

## តើខ្ញុំអាចជួយកូនឲ្យមានជោគជ័យនៅសាលាដោយវិធីណា?

រក្សាការប្រើភាសាកំណើតរបស់លោកអ្នកនៅផ្ទះ។ វាអាចជួយកូនលោកអ្នកឲ្យរៀនភាសាអង់គ្លេស បើសិនជាពួកគេអាច ស្តាប់ និយាយ អាន និងសរសេរ ភាសាកំណើតរបស់លោកអ្នក។ ការអានជាមួយកូន ហើយជជែកវែកញែកអំពីអ្វីៗដែលលោកអ្នកបាន អាន អាចជួយពួកគេឲ្យក្លាយទៅជាអ្នកចូលចិត្តអានកាន់តែច្រើនថែមទៀត។

សំខាន់បំផុត សូមសាកសួរអំពីការអប់រំរបស់កូនលោកអ្នក ហើយផ្តល់យោបល់ឲ្យគ្រូ អំពីកូនរបស់លោកអ្នក។ គ្រូរបស់កូនលោកអ្នកនឹងរីករាយដោយបានស្វែងយល់បន្ថែមទៀតអំពីកូនរបស់លោកអ្នក ហើយពេញចិត្តនឹងចែកជូនព័ត៌មានដល់លោកអ្នក អំពីអ្វីៗដែលកើតឡើងនៅក្នុងថ្នាក់រៀន!

## តើខ្ញុំអាចទាក់ទងទៅអ្នកណាដើម្បីសុំជំនួយ?

ក្រសួងអប់រំអាចជួយលោកអ្នក ដោយផ្តល់អ្នកបកប្រែភាសាតាមទូរស័ព្ទ ឬដោយផ្ទាល់ ឬក៏បកប្រែឯកសារផ្សេងៗ។ គ្រូ ESOL របស់កូនលោកអ្នកអាចឆ្លើយសំណួរអំពី ការបង្ហាត់បង្រៀននៅក្នុងថ្នាក់ ឬ ការបង្ហាត់បង្រៀន ESOL ឬការវាយតម្លៃនៃការស្ទាត់ជំនាញផ្នែកភាសា។ បើសិនជាចាំបាច់ លោកអ្នកក៏អាចទាក់ទងទៅ អ្នកគ្រប់គ្រងផ្នែកភាសាចម្រុះ នៅបណ្តាញសិក្សារបស់លោកអ្នក។